ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# សេចក្ដីប្រកាស
# របស់អ្នកនាំពាក្យព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
# ឆ្លើយតបនឹងសេចក្ដីថ្លែងការណ៍របស់ប្រធានព្រឹទ្ធសភាថៃ

១. អ្នកនាំពាក្យព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានកត់សម្គាល់ដោយសោកស្ដាយចំពោះសេចក្ដីថ្លែងការណ៍របស់ប្រធានព្រឹទ្ធសភាថៃ ប្រតិកម្មចំពោះប្រសាសន៍របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបើកសន្និសីទប្រធានសភានៃអន្តរសភាលើកទី២ (ISC-2) នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៦។

២. ប្រសាសន៍របស់ **សម្ដេចតេជោ ហ៊ុន សែន** ជាការបកស្រាយពីសភាពការណ៍ពិតដែលបាន និងកំពុងកើតមានពាក់ព័ន្ធនឹងអំពើឈ្លានពានរបស់ប្រទេសថៃមកលើបូរណភាពទឹកដីកម្ពុជា និងមានសារៈសំខាន់ជាយុទ្ធសាស្ត្រ ក្នុងការជ្រោងខ្ពស់អធិបតេយ្យជាតិ បូរណភាពទឹកដី និងការគោរពច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ ព្រមទាំងការដោះស្រាយជម្លោះដោយសន្តិវិធី។ នៅក្នុងស្មារតីនេះ អ្នកនាំពាក្យព្រឹទ្ធសភាកម្ពុជា សូមគូសបញ្ជាក់ដូចតទៅនេះ៖

**ទីមួយ** ការលើកឡើងអំពី «បញ្ហាឆបោកតាមប្រព័ន្ធអនឡាញ» គឺជាការបង្ហាញយ៉ាងច្បាស់អំពីរបៀបដែលការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ត្រូវបានប្រទេសថៃយកមកធ្វើជាហេតុផលដើម្បីប្រើប្រាស់កម្លាំង ឈ្លានពាន និងកាន់កាប់ទឹកដីកម្ពុជា។ ទោះបីជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគឺជាការចាំបាច់ និងស្របច្បាប់ក៏ដោយ ក៏កិច្ចសហប្រតិបត្តិការនេះមិនអាចយកមកប្រើប្រាស់ដើម្បីរំលងគោលការណ៍ជាមូលដ្ឋាននៃអធិបតេយ្យ បូរណភាពទឹកដី និងការហាមឃាត់ការប្រើប្រាស់កម្លាំងបានឡើយ។ ក្នុងន័យនេះ ទស្សនទានស្ដីពី «សង្គ្រាមសម័យទំនើប» គឺជាការរំលឹកថា ការបង្ខិតបង្ខំក្នុងសម័យបច្ចុប្បន្នអាចកើតមានក្នុងទម្រង់ចម្រុះ និងមានទំនាក់ទំនងគ្នា ដោយរួមបញ្ចូលទាំងការប្រើប្រាស់ហេតុផលសន្តិសុខ ប្រតិបត្តិការយោធា សង្គ្រាមព័ត៌មាន និងការប៉ុនប៉ងបង្កើតស្ថានភាពថ្មីលើដីជាក់ស្ដែង (fait accompli)។

**ទីពីរ** ការលើកឡើងអំពីការវាយប្រហារលើ សំណង់ស៊ីវិល មានសារៈសំខាន់ពីទស្សនៈនៃច្បាប់មនុស្សធម៌អន្តរជាតិ។ ប្រសិនបើទីតាំងដែលត្រូវបានអះអាងថាជាគោលដៅយោធា តាមការពិតមានលក្ខណៈជាស៊ីវិល នោះទីតាំងទាំងនោះត្រូវបានការពារក្រោមគោលការណ៍ជាមូលដ្ឋាននៃការបែងចែកឱ្យដាច់រវាងវត្ថុស៊ីវិល និងគោលដៅយោធា។ ដូច្នេះ ការវាយតម្លៃផ្លូវច្បាប់គួរតែផ្អែកលើអង្គហេតុដែលអាចផ្ទៀងផ្ទាត់បានដោយឯករាជ្យ អំពីលក្ខណៈ និងការប្រើប្រាស់ជាក់ស្ដែងនៃទីតាំងទាំងនោះ។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

**ទីបី** ចំណុចដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្របំផុត គឺការព្រមានអំពី «យុទ្ធសាស្ត្រឈ្លានពានបែបហាន់ចំណិតសាច់ក្រក» (salami-slicing strategy) ដែលសំដៅទៅលើគ្រោះថ្នាក់នៃការផ្លាស់ប្តូរស្ថានភាពនៅលើដីជាបន្តបន្ទាប់ និងបន្តិចម្តងៗ ហើយក្រោយមកត្រូវបានយកមកប្រើជាមូលដ្ឋានសម្រាប់គាំទ្រការទាមទារទឹកដី។ នេះហើយជាល្បិចកលមិនអាចប្រកែកបានរបស់ប្រទេសថៃក្នុងការបង្កើតស្ថានភាពថ្មីលើដីជាក់ស្តែងរបស់កម្ពុជា (fait accompli)។

៣. ចំពោះការអះអាងរបស់ប្រធានព្រឹទ្ធសភាថៃ ដែលថា កម្ពុជា «ជាអ្នកបាញ់មុន» ថា ថៃបានធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃសិទ្ធិស្វ័យការពារស្របច្បាប់ និងថា ថៃបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមសេចក្តីថ្លែងការណ៍រួម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ និងបានចាត់ទុកជំហររបស់កម្ពុជាថា ជាការប៉ុនប៉ង «បង្ហាញខ្លួនឯងថាជាជនរងគ្រោះ» នោះ ទាំងនេះគ្រាន់តែជាការអះអាងជាឯកតោភាគីរបស់ភាគីថៃតែប៉ុណ្ណោះ ហើយ ក៏មិនខុសប្លែកអ្វីពីការឃោសនាបំភ្លៃការពិត ប្រែក្លាយពីសទៅខ្មៅ ពីខ្មៅទៅស បំភាន់មតិសាធារណៈសំដៅបិទបាំងសកម្មភាពឈ្លានពានរបស់ខ្លួន មកលើបូរណភាពទឹកដីកម្ពុជា។ ភាគីម្ខាងមិនអាចដើរតួជាអ្នកអះអាង ហើយក្នុងពេលជាមួយគ្នានោះ ដើរតួជាអ្នកវិនិច្ឆ័យលើការអះអាងរបស់ខ្លួនឯងនោះទេ។

៤. កម្ពុជាមិនអាចទទួលយកការបកស្រាយណាមួយលើសេចក្តីថ្លែងការណ៍រួម ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០២៥ ដែលប្រែក្លាយកិច្ចព្រមព្រៀងឈប់បាញ់ ទៅជាការទទួលស្គាល់អធិបតេយ្យលើដែនដី ឬជាការទទួលស្គាល់សិទ្ធិណាមួយដែលកើតចេញពីវត្តមាន ឬការគ្រប់គ្រងដោយយោធាលើដែនដីអធិបតេយ្យរបស់កម្ពុជា ឬលើតំបន់ដែលមានជម្លោះ ឬមិនទាន់បានខណ្ឌសីមា និងកំណត់ព្រំដែនច្បាស់លាស់នោះឡើយ។

៥. បទឈប់បាញ់មិនអាចត្រូវបានយកមកធ្វើជាហេតុផល ដើម្បីបង្កើតសិទ្ធិថ្មីលើដែនដី ធ្វើឱ្យការកាន់កាប់ដែនដីដោយខុសច្បាប់ក្លាយជាស្របច្បាប់ ឬពង្រឹងស្ថានភាពដែលបង្កើតឡើងដោយឯកតោភាគីឱ្យក្លាយជាស្ថានភាពថ្មីលើដីជាក់ស្តែង (fait accompli) នោះឡើយ។ បញ្ហាអធិបតេយ្យ និងការកំណត់ព្រំដែន ត្រូវតែដោះស្រាយដោយអនុលោមតាមសន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលអាចអនុវត្តបាន ច្បាប់អន្តរជាតិ និងយន្តការដោះស្រាយជម្លោះដោយសន្តិវិធីដែលមានសម្រាប់ភាគីទាំងពីរ។

៦. សេចក្តីថ្លែងការណ៍របស់ប្រធានព្រឹទ្ធសភាថៃក៏បានលើកឡើងផងដែរថា ជម្លោះនេះ «**មិនគួរត្រូវបានធ្វើអន្តរជាតូបនីយកម្មឡើយ**»។ កម្ពុជាគ្មានបំណងធ្វើឱ្យវិវាទទ្វេភាគីក្លាយជាបញ្ហាអន្តរជាតិ ដើម្បីបម្រើគោលបំណងនយោបាយណាមួយឡើយ។ ប្រសិនបើថៃពិតជាមានបំណងចង់បញ្ចៀសការយកចិត្តទុកដាក់បន្ថែមទៀតពីសហគមន៍អន្តរជាតិចំពោះស្ថានការណ៍នេះ មធ្យោបាយដែលមានប្រសិទ្ធភាពបំផុត មិនមែនជាការទាមទារឱ្យកម្ពុជានៅស្ងៀមនោះទេ ប៉ុន្តែគឺត្រូវដោះស្រាយមូលហេតុ និងស្ថានភាពជាក់ស្តែងដែលបានបង្កឱ្យមានការព្រួយបារម្ភទាំងនេះ ពោលគឺ៖ ដកកងកម្លាំងរបស់ខ្លួនចេញពីទឹកដីកម្ពុជា បញ្ឈប់រាល់សកម្មភាពដែលផ្លាស់ប្តូរស្ថានភាពនៅលើដី ឬបង្កើតជាស្ថានភាព

ថ្មីលើដីជាក់ស្តែង ( fait accompli ) និងអនុញ្ញាតឱ្យប្រជាជនស៊ីវិលកម្ពុជាភៀសខ្លួនអាចវិលត្រឡប់ទៅកាន់លំនៅឋានរបស់ខ្លួនវិញដោយសុវត្ថិភាព និងដោយសេចក្តីថ្លៃថ្នូរ។

៧. ការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិ មិនមែនជាមូលហេតុនៃបញ្ហានោះទេ ប៉ុន្តែជាផលវិបាកនៃស្ថានភាពជាក់ស្តែងនៅលើដី។ ដូច្នេះ មធ្យោបាយដ៏ប្រាកដប្រជាបំផុតដើម្បីកុំឱ្យបញ្ហានេះបន្តក្លាយជាក្តីព្រួយបារម្ភរបស់សហគមន៍អន្តរជាតិ គឺត្រូវស្តារឡើងវិញនូវការគោរពអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា អនុវត្តឱ្យបានពេញលេញនូវច្បាប់អន្តរជាតិ និងការប្តេជ្ញាចិត្តដែលមានស្រាប់ ព្រមទាំងដោះស្រាយរាល់បញ្ហាដែលនៅសេសសល់ដោយសន្តិវិធី តាមរយៈយន្តការដែលមានស្រាប់ និងសមស្របនានា។

៨. នៅក្នុងបរិបទនេះ ការប្រើប្រាស់យន្តការតំបន់ និងអន្តរជាតិប្រកបដោយការទទួលខុសត្រូវ មិនគួរត្រូវបានចាត់ទុកថាជាការប្រឈមមុខដាក់គ្នានោះទេ។ នីតិវិធីផ្លូវច្បាប់ និងការទូតដោយសន្តិវិធី ត្រូវបានបង្កើតឡើងក្នុងគោលបំណងជាក់លាក់ ដើម្បីជួយឱ្យផ្ទៃនានាបញ្ជាក់ឱ្យបានច្បាស់នូវជំហររបស់ខ្លួន ទប់ស្កាត់ការកើនឡើងនៃភាពតានតឹង កាត់បន្ថយការយល់ច្រឡំ និងដោះស្រាយវិវាទដោយមានរបៀបរៀបរយ និងស្របតាមច្បាប់។ យន្តការទាំងនេះក៏រួមចំណែកដល់ការស្វែងរកដំណោះស្រាយប្រកបដោយយុត្តិធម៌ និងយូរអង្វែងផងដែរ។ យន្តការបែបនេះជួយពង្រឹងទំនុកចិត្តតាមរយៈការលើកកម្ពស់តម្លាភាព គណនេយ្យភាព ភាពច្បាស់លាស់ផ្នែកច្បាប់ និងការអត់ធ្មត់។ ច្បាប់អន្តរជាតិនៅតែជាខែលការពារដ៏សំខាន់ប្រឆាំងនឹងការបង្ខិតបង្ខំ ភាពមិនច្បាស់លាស់ និងការប្រើប្រាស់អំណាចដោយបំពាន។

៩. កម្ពុជាយល់ស្របថា ការជឿទុកចិត្តគ្នា ការអត់ធ្មត់ ភាពស្មោះត្រង់ និងសុចរិតភាព គឺជាកត្តាចាំបាច់សម្រាប់ទំនាក់ទំនងដោយសន្តិភាពរវាងប្រទេសជិតខាង។ ទោះជាយ៉ាងណា ការកសាងទំនុកចិត្តត្រូវតែមានទៅវិញទៅមក និងបង្ហាញឱ្យឃើញតាមរយៈទង្វើដែលមានសង្គតិភាព មិនមែនត្រឹមតែពាក្យសម្តីនោះទេ។ មិនអាចរំពឹងឱ្យតែភាគីម្ខាងកសាងទំនុកចិត្តបានឡើយ ខណៈដែលនីតិវិធីប្រកបដោយអព្យាក្រឹតភាពត្រូវបានរារាំង ត្រូវបានបកស្រាយតាមការជ្រើសរើសយកតែអ្វីដែលផ្តល់ប្រយោជន៍ដល់ខ្លួន ឬត្រូវបានបោះបង់ចោលនោះទេ។ ដូចគ្នានេះដែរ ការអំពាវនាវឱ្យមានកិច្ចសន្ទនាក៏មិនអាចគួរឱ្យជឿទុកចិត្តបានដែរ ខណៈដែលសកម្មភាពជាក់ស្តែងនៅនឹងកន្លែងបង្កើនភាពតានតឹង និងបំផ្លាញទំនុកចិត្ត។ ដោយហេតុនេះ ការគោរពច្បាប់អន្តរជាតិ និងការដោះស្រាយវិវាទដោយសន្តិវិធី នៅតែជាកត្តាចាំបាច់មិនអាចខ្វះបានសម្រាប់សន្តិភាព និងស្ថិរភាពយូរអង្វែង។

ភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២៦